**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបុណ្យនៅពោធិ៍ចិនតុង**
**ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៨**
*សិរីរុងរឿងរបស់ព្រះជាម្ចាស់*

អត្ថបទទី១៖ យរ ៣១,៣១-៣៤
អត្ថបទទី២៖ ហាប ៥,៧-៩
ដំណឹងល្អ៖ យហ ១២,២០-៣៣

បងប្អូនជាទីស្រឡាញ់!

យើងប្រើធូបនៅក្នុងពិធីបុណ្យ ដើម្បីបង្ហាញពីវត្តមានរបស់ព្រះជាម្ចាស់ និងធូបនេះជាសញ្ញាសម្គាល់ពីសិរីរុងរឿងរបស់ព្រះជាម្ចាស់។

ថ្ងៃនេះ ក្នុងគម្ពីរដំណឹងល្អ "**ព្រះបិតាយាងមក ដើម្បីបង្ហាញអំពីសិរីរុងរឿងរបស់ព្រះជាម្ចាស់**"។ នៅក្នុងពិធីបុណ្យ យើងប្រើធូបដើម្បីបង្ហាញថា ពិតមែនព្រះនាមរបស់ព្រះជាម្ចាស់ពោរពេញដោយសិរីរុងរឿង។ ថ្ងៃនេះ មានគេសុំជួបជាមួយព្រះយេស៊ូ គេចង់ឃើញព្រះយេស៊ូ គេចង់ស្គាល់ព្រះយេស៊ូ។ ប៉ុន្តែព្រះយេស៊ូថ្ងៃនេះមានចម្លើយប្លែកៗ៖

**ទីមួយ** សាសនាដទៃហ្នឹង មិនអនុញ្ញាតឲ្យឃើញ យើងបានស្តាប់ព្រះសូរសៀងមួយយ៉ាងពិសេសនៅថ្ងៃនេះ "**យើងបានសម្តែងសិរីរុងរឿងរបស់យើង ហើយយើងនឹងសម្តែងសិរីរុងរឿងសារជាថ្មី**" នៅជុំវិញឈើឆ្កាង យើងឃើញទេវទូតកំពុងអធិដ្ឋាន ច្រៀងកោតសរសើរព្រះជាម្ចាស់ មានព្រះអាទិត្យ មានពន្លឺរស្មី សរុបមកគឺ "**សម្តែងសិរីរុងរឿងរបស់ព្រះជាម្ចាស់**"។ ប៉ុន្តែ នៅពេលខ្ញុំនិយាយពីសិរីរុងរឿង មានការអស្ចារ្យមួយ យើងនឹកឃើញដល់ស្តេចមួយដែលកោតសរសើរនៅលើបល្ល័ង្ក យើងនឹកឃើញដល់លោកធំដែលយើងកោតសរសើរយើងគោរព យើងនឹកឃើញដល់អ្នកដឹកនាំដែលយើងគោរពជានិច្ច។ យើងកំពុងមើលសិរីរុងរឿងរបស់ព្រះយេស៊ូប្លែក ដោយសារសិរីរុងរឿងដែលយើងមើលឃើញព្រះយេស៊ូជាមនុស្សសុចរឹត ព្រះយេស៊ូដែលត្រូវគេឆ្កាង ព្រះយេស៊ូដែលសោយព្រះទិវង្គត ព្រះយេស៊ូដែលដាក់ខ្លួនដល់កំពូល។ ប្រសិនបើយើងមើលនៅក្រោមបន្តិចយើងឃើញ ព្រះយេស៊ូកំពុងជប់លៀងជាមួយក្រុមគ្រីស្តទូត ព្រះយេស៊ូបានឲ្យនំប៉័ងរួចថា "**នេះជាព្រះកាយរបស់ខ្ញុំ**" ឲ្យស្រាដោយថា "**នេះជាលោហិតរបស់ខ្ញុំ**"។ ព្រះយេស៊ូកំពុងឲ្យជីវិត និងមុនព្រះយេស៊ូជប់លៀងជាមួយក្រុមគ្រីស្តទូត ព្រះយេស៊ូបានលាងជើងឲ្យសាវ័ក។ ដូច្នេះ ប្រសិនបើយើងគិតពីសិរីរុងរឿងតាមរបៀបមនុស្ស គឺកោតសរសើរ អបអរសាទរមនុស្សដែលមានអំណាច

មនុស្សដែលត្រូវគេគោរព ដោយសារគេគ្រប់គ្រងយើងយ៉ាងខ្លាំង។ ប៉ុន្តែ ថ្ងៃនេះយើងមើល សិរីរុងរឿងរបស់ព្រះយេស៊ូ ដែលប្លែកមែនទែនគឺ ព្រះយេស៊ូដែលលាងជើង ដាក់ខ្លួន បម្រើ ស្រឡាញ់ ដែលឲ្យជីវិត និងសោយព្រះទិវង្គតលើឈើឆ្កាង។ នេះ ជាសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងជាមូលហេតុដែលត្រូវប្រើធូប នៅពេលខ្ញុំទេសនាហើយយើងនឹងអុជធូប ដើម្បីឲ្យផ្សែងឡើងកោតសរសើរព្រះជាម្ចាស់ និងណែនាំឲ្យយើងគិតអំពីជីវិតរបស់យើង។

អត្ថបទទីមួយ "**យើងនឹងឆ្លាក់វិន័យនៅក្នុងចិត្តរបស់ពួកគេ នឹងធ្វើជាព្រះរបស់ពួកគេ ហើយពួកគេនឹងទៅជាប្រជារាស្ត្ររបស់យើង**"។ ព្រះជាម្ចាស់ បានឆ្លាក់ធម្មវិន័យនៃសេចក្តីស្រឡាញ់នៅក្នុងដួងចិត្តរបស់យើង។ ព្រះយេស៊ូ បានឆ្លាក់ធម្មវិន័យនៃសេចក្តីស្រឡាញ់នេះដល់យើងជាគ្រីស្តបរិស័ទ តាំងពីថ្ងៃដែលយើងទទួលពិធីជ្រមុជទឹកហើយឲ្យដើរតាមព្រះយេស៊ូ។ យើងដឹងហើយថា ដើម្បីឲ្យពូជមានផ្លែ យើងត្រូវការងាប់សិន ពេលគេសាបព្រោះ គ្រាប់ពូជចូលទៅក្នុងដី សាបព្រោះគ្រាប់ពូជមួយគ្រាប់ នឹងចេញស្រូវយ៉ាងច្រើនដើម្បីច្រូត។ ថ្ងៃនោះព្រះយេស៊ូនិយាយថា "**យើងត្រូវការងាប់**" គឺងាប់អារម្មណ៍របស់យើង អ្វីដែលជាផ្លូវវងវេងនៅក្នុងជីវិតយើង ដើម្បីឲ្យក្លាយជាមនុស្សថ្មីដែលស្អាតជាងមុន។ ដោយសារពេលយើងជាប់ជាមួយព្រះយេស៊ូ យើងទៅជាមនុស្សសុចរិត ជាមនុស្សល្អ ជាមនុស្សដ៏ជាទីស្រឡាញ់ ជាមនុស្សដែលចេះចែករំលែកជីវិត ដូចព្រះយេស៊ូបានចែករំលែកជីវិត។ នៅក្នុងរដូវ៤០ថ្ងៃ ព្រះសហគមន៍ណែនាំឲ្យយើងអធិដ្ឋាន តមអាហារ ជួយដល់បងប្អូនឯទៀតៗ ដើម្បីបំផ្លាញអំពើបាបដែលមាននៅក្នុងដួងចិត្តរបស់យើង ឲ្យរៀនធ្វើជាមនុស្សថ្មី។ នៅពេលយើងសុខចិត្តលះបង់ចោល ពេលយើងសុខចិត្តសម្លាប់អំពើបាបរបស់យើង យើងនឹងទៅជាមនុស្សថ្មី ពោរពេញដោយកម្លាំង ពោរពេញដោយសេចក្តីស្រឡាញ់ ពោរពេញដោយថាមពល ដើម្បីចែករំលែកអំណរជាមួយបងប្អូនឯទៀតៗ។

ដូច្នេះថ្ងៃនេះ យើងអរព្រះគុណព្រះជាម្ចាស់ ដែលណែនាំឲ្យយើងធ្វើដំណើរជាមួយព្រះអង្គ។ យើងនឹកឃើញ នៅក្នុងអភិបូជាយើងធ្វើសក្ការបូជារបស់ព្រះយេស៊ូ ដែលថ្វាយជីវិតនៅលើឈើឆ្កាង ដើម្បីឲ្យយើងទាំងអស់មានជីវិតដ៏បរិបូរណ៍។ ថ្ងៃនេះ យើងស្តាប់នៅក្នុងគម្ពីរ ព្រះយេស៊ូមិនគេចខ្លួន មិនលាក់ខ្លួន ព្រះយេស៊ូសុខចិត្តសម្រាប់យើងរៀងៗខ្លួនដោយសុខចិត្តស្លាប់ ដើម្បីឲ្យយើងមានជីវិតដ៏បរិបូរណ៍។ ថ្ងៃនេះ យើងយល់ហើយ សិរីរុងរឿងរបស់ព្រះជាម្ចាស់ គឺធ្វើយ៉ាងម៉េចដើម្បីលះបង់ចោលផលប្រយោជន៍ លះបង់ចោល

អំពើបាប លះបង់ចោលចិត្តលោភលន់ អាត្មានិយមដែលនៅពេញក្នុងដួងចិត្តរបស់យើង ដើម្បីធ្វើជាមនុស្សថ្មីជាមួយព្រះយេស៊ូ និងដើម្បីឲ្យពិភពលោករបស់យើងយល់ថា នៅពេលយើងបម្រើអ្នកដទៃ នៅពេលដែលយើងស្រឡាញ់បងប្អូនឯទៀតអស់ពីដួងចិត្ត ណែនាំឲ្យពិភពលោករបស់យើងមានសេចក្តីសង្ឃឹម។ សិរីរុងរឿងរបស់ព្រះជាម្ចាស់ គឺលះបង់ចោល ស្រឡាញ់ លើកលែងទោស បម្រើ ដើម្បីឲ្យបងប្អូនឯទៀតៗមានសេចក្តីសង្ឃឹម និងអំណរសប្បាយ។ នេះជាអ្វី ដែលព្រះជាម្ចាស់បានណែនាំឲ្យយើងរស់នៅក្នុងរដូវ៤០ថ្ងៃ សិរីរុងរឿងរបស់ព្រះជាម្ចាស់គឺ បូជាជីវិតនៅលើឈើឆ្កាង ដើម្បីឲ្យយើងទាំងអស់មានជីវិតអស់កល្បជានិច្ច។ មិនមែនសិរីរុង ដែលនាំឲ្យយើងមានអំណាច ណែនាំឲ្យគ្រប់គ្រងមនុស្សដែលអត់ចេះអាណិតមេត្តា។ សិរីរុងរឿងរបស់ព្រះជាម្ចាស់ គឺព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ដើម្បីឲ្យយើងទាំងអស់មានសេចក្តីសុខ និងសេចក្តីសង្ឃឹម។ ដូច្នេះ យើងអធិដ្ឋានទៅព្រះជាម្ចាស់ ដើម្បីឲ្យយើងទាំងអស់ទៅជាមនុស្សថ្មី ដើម្បីបង្ហាញពីសិរីរុងរឿរបស់ព្រះជាម្ចាស់ ដើម្បីឲ្យមនុស្សយើងរកឃើញសេចក្តីសង្ឃឹម និងសុខសន្តិភាព។ អាម៉ែន៕